ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ព្រះរាជក្រឹត្យ

# ស្តីពី

# ការកំណត់ស្តង់ដាគោលជាតិកីឡាក្រាម

Www.KhmerFamous.Com

ក្រសួងអភិវឌ្ឍន៍ជនបទ
ចូល
លេខៈ ១៤០៤ ក.អ.ជ
ថ្ងៃទី ១៧.៨.១៤ ម៉ោង ៩
បញ្ជូន អ.វ.ប

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៤/៩៧០

## ស្តីពី
## ការកំណត់ស្តង់ដាគោលជាតិគីឡូក្រាម

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៦ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមាត្រាសាស្ត្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្មនិងសិប្បកម្ម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៤

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

# ត្រាស់បង្គាប់

**មាត្រា១ .-**

ត្រូវបានកំណត់ស្តង់ដាគោលជាតិគីឡូក្រាមដែលត្រូវតម្កល់ទុកនៅមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ (**ម.ម.ជ.**) មានអត្តសញ្ញាណ ដូចខាងក្រោម៖

| | | |
|---|---|---|
| លេខសម្គាល់ | : | ២៣៤០២០៤ |
| ទម្ងន់ | : | ១(មួយ)គីឡូក្រាម |
| ផលិតនៅ | : | ប្រទេសអាល្លឺម៉ង់ |
| ចំណាត់ថ្នាក់ | : | អឺសូន្យ(E0) |
| វត្ថុធាតុផ្សំ | : | សំលោហធាតុពិសេសដែលមិនច្រេះ |

អត្តសញ្ញាណនៃស្តង់ដាគោលជាតិគីឡូក្រាមមានភ្ជាប់ជាឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ។

**មាត្រា២ .-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី១៤ ខែ សីហា ឆ្នាំ២០១៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១៤០៨.១០១០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ:១០២៤.ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ឧបសម្ព័ន្ធ

## នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៤/៩៧០ ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០១៤

## ស្តីពីការកំណត់ស្តង់ដាគោលជាតិគីឡូក្រាម

### ស្តង់ដាគោលជាតិគីឡូក្រាមទម្ងន់១គ.ក្រ. ថ្នាក់ E0



### ប្រអប់សម្រាប់ថែរក្សាស្តង់ដាគោលជាតិគីឡូក្រាមពេលបញ្ជូនទៅធ្វើព្យាសកម្ម




